# លិខិតចំហ

## សូមគោរពជូន

## ឯកឧត្តម លោកជំទាវនៃបណ្តារដ្ឋប្រជាធិបតេយ្យធំៗទាំង១៣

### ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០

យើងខ្ញុំជាអង្គការសង្គមស៊ីវិលអន្តរជាតិ និងសមាគមអ្នកបញ្ញាទិញសរុបចំនួន ៣៣ ដែលមានរាយនាមខាងក្រោម សូមស្នើដល់តំណាងរដ្ឋាភិបាលនៃប្រទេស**អូស្រ្តាលី កាណាដា ហ្វាំងឡង់ បារាំង អាល្លឺម៉ង់ ឥណ្ឌា ជប៉ុន ណូវែហ្សេឡង់ ស៊ុយអែត ហូឡង់ សាធារណរដ្ឋកូរ៉េ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក** ចូលរួមជាមួយសហភាពអឺរ៉ុបក្នុងការអំពាវនាវឱ្យមានការគោរពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ សហភាពអឺរ៉ុបនឹងព្យួរផ្នែកខ្លះនៃ «ការអនុគ្រោះពន្ធលើមុខទំនិញទាំងអស់លើកលែងតែសព្វាវុធ» ដល់ប្រទេសកម្ពុជា ដែលជាការឆ្លើយតបទៅនឹង «ការរំលោភបំពានធ្ងន់ធ្ងរ និងមានលក្ខណៈជាប្រព័ន្ធ» ទៅកតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិចំនួនបួនសំខាន់ៗស្តីពីសិទ្ធិមនុស្ស និងសិទ្ធិការងាររួមមាន៖ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ឆ្នាំ១៩៦៦), អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ៨៧ ស្តីពីសេរីភាពខាងសមាគម និងកិច្ចការពារសិទ្ធិក្នុងការចងក្រង (ឆ្នាំ១៩៤៨), អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ៩៨ ស្តីពីការអនុវត្តគោលការណ៍សិទ្ធិក្នុងការចងក្រង និងចរចាកិច្ចព្រមព្រៀងរួម (ឆ្នាំ១៩៤៩), និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ឆ្នាំ១៩៦៦)។

រដ្ឋាភិបាលនៃប្រទេសកម្ពុជាបន្តបង្ក្រាបលើសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ គណបក្សជំទាស់ និងអ្នកការពារសិទ្ធិមនុស្សដើម្បីបំបិទសំឡេងរិះគន់នៅក្នុងប្រទេស។ ក្នុងរយៈពេល ៣ ឆ្នាំ កន្លងមកនេះ រដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ ដែលមានលក្ខណៈគាបសង្កត់ជាបន្តបន្ទាប់ ដែលរឹតត្បិតពុំត្រឹមត្រូវដល់សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋខ្មែរ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៩ អាជ្ញាធរនៃប្រទេសកម្ពុជាបានឃុំខ្លួនប្រជាពលរដ្ឋខ្លួនជិត ៩០ នាក់តាមអំពើចិត្ត ដោយបំពានលើមូលដ្ឋាននៃការបញ្ចេញមតិ ឬទស្សនៈនយោបាយដោយសន្តិវិធី ក៏ដូចជាការចូលរួមក្នុងជីវភាពនយោបាយរបស់ពួកគាត់[1]។ ទោះបីជាសមាជិកគណបក្សជំទាស់ចំនួន ៧៤ រូប ដែលត្រូវបានឃុំខ្លួនពីបទចោទប្រកាន់ដែលគ្មានមូលដ្ឋានច្បាស់លាស់ទាំងនោះត្រូវបានដោះលែងវិញនៅខែធ្នូ ឆ្នាំ២០១៩[2]យ៉ាងណាក្តី ក៏ការចោទប្រកាន់លើពួកគាត់ពុំទាន់ទម្លាក់ចោលនៅឡើយ ហើយពួកគាត់ប្រឈមនឹងការចាប់ខ្លួនជាថ្មីទៀត។ សវនាការព្រហ្មទណ្ឌលើលោក កឹម សុខា ដែលជាមេដឹកនាំគណបក្សជំទាស់ដែលត្រូវជាប់ចោទពីក្បត់ជាតិដោយពុំមានមូលដ្ឋានប្រព្រឹត្តទៅដោយមានភាពមិនប្រក្រតីជាច្រើន ចាប់តាំងពីខែមករាដើមឆ្នាំនេះ។ លោក កឹម សុខា នៅតែត្រូវបានហាមឃាត់មិនឱ្យចូលរួមក្នុងជីវភាពនយោបាយ និងប្រឈមនឹងការជាប់ពន្ធនាគាររយៈពេល ៣០ ឆ្នាំ ប្រសិនជាត្រូវ

---

[1] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, «អ្នកទោសនយោបាយកម្ពុជា» ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០ https://www.hrw.org/video-photos/interactive/ 2020/01/24/political-prisoners-cambodia

[2] ហ៊ុល រស្មី, «សកម្មជន និងសមាជិកនៃគណបក្សជំទាស់យ៉ាងតិច៧៤នាក់ត្រូវបានដោះលែងបន្ទាប់ពីមានបទបញ្ជាពីលោក ហ៊ុន សែន» *វីអូអេ ខ្មែរ* ថ្ងៃទី៨ វិច្ឆិកា ឆ្នាំ២០១៩ https://www.voacambodia.com/a/at-least-74-opposition-activists-and-members-released-after-hun-sen-directive/5170258.html

បានផ្តន្ទាទោសពីបទក្បត់ជាតិមែននោះ។ លោកនាយករដ្ឋមន្ត្រីប្រទេសកម្ពុជាបានលើកឡើងកន្លងទៅថា សវនាការនេះអាចអូសបន្លាយរហូតដល់ឆ្នាំ២០២១។[3]

នៅខែមេសា រដ្ឋាភិបាលកម្ពុជាបានយកហេតុផលនៃវិបត្តិជំងឺរាតត្បាតកូវីដ-១៩ ដើម្បីអនុម័តច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នដែលមានលក្ខណៈរឹតត្បិតធ្ងន់ធ្ងរ និងផ្តល់អំណាចដ៏ទូលំទូលាយដល់អាជ្ញាធរកម្ពុជា ក្នុងការរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងការចងក្រងសមាគម ដែលសិទ្ធិទាំងនេះត្រូវបានរឹតត្បិតយ៉ាងខ្លាំងរួចទៅហើយក្នុងរយៈពេល ៣៥ ឆ្នាំ នៃការគ្រប់គ្រងអំណាចរបស់បក្សកាន់អំណាច[4]។ បច្ចុប្បន្ននេះ មានអ្នកទោសនយោបាយចំនួន ៣០ រូប កំពុងស្ថិតក្នុងការឃុំខ្លួននៅពន្ធនាគារដោយសារតែការបង្រ្កាបដ៏ខ្លាំងក្លាជាបន្តបន្ទាប់របស់រដ្ឋាភិបាលកម្ពុជាទៅលើសេរីភាពខាងការបញ្ចេញមតិក្នុងពេលនៃការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩[5]។

ប្រទេសកម្ពុជាបានប្តេជ្ញាក្នុងការការពារ និងការលើកកម្ពស់សិទ្ធិមនុស្សជាមូលដ្ឋាន ដែលផ្តល់ការការពារដោយស្មើភាពគ្នាតាមផ្លូវច្បាប់ ហើយនិងការរៀបចំការបោះឆ្នោតពិតប្រាកដតាមកាលកំណត់ នៅពេលដែលប្រទេសនេះបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ រដ្ឋាភិបាលកម្ពុជាក៏ជារដ្ឋភាគីមួយនៃអនុសញ្ញាស្នូលនានារបស់អង្គការពលកម្មអន្តរជាតិផងដែរ ដែលការពារសិទ្ធិរបស់កម្មករនិយោជិត និងសហជីព។ ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋមានសារៈសំខាន់ជាខ្លាំងដល់ការធានាដល់បរិយាកាសធុរកិច្ចដែលមានស្ថិរភាព និងរីកលូតលាស់ក្នុងរយៈពេលយូរអង្វែង។

ប្រទេសកម្ពុជាបានឯកភាពថា ការទទួលបានការអនុគ្រោះពន្ធលើមុខទំនិញទាំងអស់លើកលែងតែសព្វាវុធរបស់សហភាពអឺរ៉ុប គឺមានភ្ជាប់នូវលក្ខខណ្ឌតម្រូវលើការប្រតិបត្តិខ្ជាប់ខ្ជួនតាមគោលការណ៍នានាមានចែងនៅក្នុងអនុសញ្ញា និងកតិកាសញ្ញាស្នូលស្តីពីសិទ្ធិការងារ និងសិទ្ធិមនុស្សចំនួន១៥។ សេចក្តីសម្រេចរបស់គណៈកម្មការអឺរ៉ុបនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ អំពីការដកភាពអនុគ្រោះពន្ធផ្នែកខ្លះនៃមុខទំនិញទាំងអស់លើកលែងតែសព្វាវុធដល់ប្រទេសកម្ពុជា បានធ្វើឡើងបន្ទាប់ពីដំណើរ «ការចូលរួមក្នុងការកែលម្អស្ថានភាព» រយៈពេល ១ ឆ្នាំ រវាងសហភាពអឺរ៉ុប និងប្រទេសកម្ពុជា ដែលក្នុងអំឡុងពេលនោះសហភាពអឺរ៉ុបបានផ្តល់ឱកាសគ្រប់យ៉ាងដល់រដ្ឋាភិបាលកម្ពុជាក្នុងការសហការ និងបង្កើតវឌ្ឍនៈភាពសំខាន់ៗក្នុងការធ្វើឱ្យប្រសើរឡើងដល់កិច្ចការពារសិទ្ធិមនុស្ស និងសិទ្ធិការងារ។ គណៈកម្មការអឺរ៉ុបបានធ្វើសេចក្តីសន្និដ្ឋានថា ប្រទេសកម្ពុជាពុំបានចាត់វិធានការចាំបាច់ក្នុងការរក្សាការអនុគ្រោះពន្ធលើមុខទំនិញទាំងអស់លើកលែងតែសព្វាវុធឱ្យស្ថិតនៅពេញលេញនោះទេ។

យើងខ្ញុំឯកភាពជាមួយសេចក្តីសន្និដ្ឋាននោះ។ ករណីឧទាហរណ៍មួយ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ក្រុមហ៊ុន និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២៣ ក្នុងនោះរួមមានទាំងក្រុមហ៊ុនបញ្ញាទិញសម្លៀកបំពាក់ជាអន្តរ

---

[3] សូមអាន៖ «លោកនាយករដ្ឋមន្ត្រីលើកឡើងថា ករណីលោក កឹម សុខា អាចអូសបន្លាយដល់ឆ្នាំក្រោយ» *ខ្មែរថាម៍* ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ https://www.khmertimeskh.com/723984/sokhas-case- could-be-delayed-until-next-year-prime-minister/

[4] វិចារណៈកថាព័ត៌មានរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា «អ្នកជំនាញអង្គការសហប្រជាជាតិថាច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងគ្រាអាសន្នប៉ះពាល់ធ្ងន់ដល់សិទ្ធិមនុស្ស» ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០។

[5] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, «បញ្ជីអ្នកចាប់ខ្លួន និងអ្នកជាប់ឃុំដោយសារតែបទល្មើសពាក់ព័ន្ធនឹងជំងឺកូវីដ ១៩» ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ https://www.hrw.org/video-photos/interactive/2020/01/24/political-prisoners-cambodia

ជាតិធំៗផងដែរ បានលើកឡើងនូវក្តីបារម្ភអំពីស្ថានភាពនៃសិទ្ធិការងារ និងបានស្នើឱ្យរដ្ឋាភិបាលកម្ពុជាធ្វើវិសោធនកម្ម ឬនិរាករណ៍ច្បាប់ដែលមានភាពចម្រូងចម្រាសចំនួនពីរ ពោលគឺ ច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ច្បាប់អង្គការសមាគម) និងស្នើឱ្យទម្លាក់ចោលរាល់ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌនានាលើថ្នាក់ដឹកនាំសហជីព[6]។ ការធ្វើវិសោធនកម្មតិចតួចលើច្បាប់ស្តីពីសហជីពដែលមានលក្ខណៈរឹតត្បិតរបស់រដ្ឋាភិបាលកម្ពុជានោះ ពុំឆ្លើយតបឱ្យបានពេញលេញទៅនឹងកម្មវត្ថុនៃសំណើរបស់ក្រុមអ្នកបញ្ជាទិញដែលចាំបាច់ក្នុងការដោះស្រាយបញ្ហាសិទ្ធិការងារនោះឡើយ។ លើសពីនេះទៀត រដ្ឋាភិបាលកម្ពុជាពុំបានបង្ហាញឆន្ទៈក្នុងការចាត់វិធានការជាក់លាក់ និងប្រកបដោយអត្ថន័យដើម្បីកែលម្អស្ថានភាពសិទ្ធិមនុស្សឡើយ តែផ្ទុយទៅវិញប្រទេសកម្ពុជាបានបន្តអនុម័តច្បាប់ដែលមានលក្ខណៈគាបសង្កត់មួយចំនួនថែមទៀត ព្រមទាំងបានចាប់ខ្លួនអ្នកតវ៉ាដោយសន្តិវិធីមួយចំនួនទៀតផងនៅក្នុងអំឡុងពេលដែលសហភាពអឺរ៉ុបកំពុងតាមដាន និងវាយតម្លៃយ៉ាងយកចិត្តទុកដាក់។

ហេតុដូច្នោះហើយ យើងខ្ញុំសូមស្នើរដ្ឋាភិបាលនៃប្រទេស**អូស្ត្រាលី កាណាដា ហ្វាំងឡង់ បារាំង អាល្លឺម៉ង់ ឥណ្ឌា ជប៉ុន ណូវែហ្សេឡង់ ស៊ុយអែត ហូឡង់ សាធារណរដ្ឋកូរ៉េ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក** បំពេញតួនាទីជាលក្ខណៈពហុភាគី និងទ្វេភាគី ដើម្បីចូលរួមជាមួយសហភាពអឺរ៉ុបក្នុងការអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជាចាត់វិធានការជាក់លាក់យ៉ាងឆាប់រហ័សក្នុងការដោះស្រាយបញ្ហាសិទ្ធិមនុស្ស ដូចខាងក្រោម៖

១. **ដោះលែងអ្នកទោសនយោបាយទាំងអស់ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ ក្នុងនោះរួមមានទាំងសកម្មជនអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងសមាជិកនៃគណបក្សជំទាស់។**

២. **បញ្ឈប់ការយាយី ការចាប់ខ្លួនដោយបំពាន និងការវាយដំលើរាងកាយលើថ្នាក់ដឹកនាំសហជីព សកម្មជនដីធ្លី អ្នកការពារសិទ្ធិមនុស្ស សមាជិកនៃគណបក្សជំទាស់ និងអ្នកសារព័ត៌មាន។**

៣. **ទម្លាក់ចោលការចោទប្រកាន់ពីបទក្បត់ជាតិដែលគ្មានមូលដ្ឋានច្បាស់លាស់លើលោក កឹម សុខា មេដឹកនាំគណបក្សជំទាស់។**

៤. **ស៊ើបអង្កេតដោយឯករាជ្យ ឥតលម្អៀង ជាបន្ទាន់ និងហ្មត់ចត់ក្នុងករណីវាយប្រហារនានា ក្នុងនោះរួមទាំងឃាតកម្មលើអ្នករិះគន់រដ្ឋាភិបាល និងនាំខ្លួនជនប្រព្រឹត្តទាំងនោះមកទទួលខុសត្រូវចំពោះមុខច្បាប់។** ឧទាហរណ៍ រដ្ឋាភិបាលកម្ពុជាគប្បីបង្កើតគណៈកម្មាធិការឯករាជ្យមួយដើម្បីស៊ើបអង្កេតដោយប្រសិទ្ធភាពក្នុងករណីសម្លាប់ក្រៅប្រព័ន្ធច្បាប់លើលោកបណ្ឌិត **កែម ឡី** អ្នកវិភាគនយោបាយ និងអ្នកការពារសិទ្ធិមនុស្ស ដែលត្រូវបានឃាតករបាញ់សម្លាប់ក្នុងខែកក្កដា ឆ្នាំ២០១៦។

៥. **និរាករណ៍ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។**

[6] លិខិតផ្តួចផ្តើមដោយសមាគមពលកម្មយុត្តិធម៌ ផ្ញើជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ និងមានគាំទ្រពីសមាគមសម្លៀកបំពាក់ និងស្បែកជើងអាមេរិក ក្រុមរៀបចំកិច្ចព្រមព្រៀងលើវិស័យការងារ និងសម្លៀកបំពាក់ប្រកបដោយនិរន្តរភាព និងក្រុមហ៊ុនបញ្ជាទិញទំនិញពីកម្ពុជាចំនួន១៥ https://www.fairlabor.org/sites/default/files/2020-01-22_letter_to_pm_hun_sen.pdf

៦. **ធ្វើវិសោធនកម្មលើវិសោធនកម្មច្បាប់លើច្បាប់ស្តីពីគណបក្សនយោបាយដែលបានធ្វើវិសោធនកម្មចំនួនបីលើកចុងក្រោយនេះ** ដែលអនុញ្ញាតឱ្យធ្វើការរម្លាយគណបក្សនយោបាយ និងហាមប្រាមថ្នាក់ដឹកនាំពីការធ្វើការសកម្មភាពនយោបាយដោយពុំត្រឹមត្រូវ។

៧. **ធ្វើវិសោធនកម្មស៊ីជម្រៅលើច្បាប់ស្តីពីសហជីព** ដោយពិគ្រោះយោបល់ជាមួយកម្មករនិយោជិត អ្នកតស៊ូមតិក្នុងវិស័យការងារ និងដៃគូពាក់ព័ន្ធដើម្បីឱ្យបានស្របយ៉ាងពេញលេញតាមអនុសញ្ញាលេខ៨៧ នៃអង្គការពលកម្មអន្តរជាតិ (សេរីភាពក្នុងការចងក្រងសមាគម) និងអនុសញ្ញាលេខ៩៨ (សិទ្ធិក្នុងការចងក្រង និងការចរចាអនុសញ្ញារួម) ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នហើយ។

៨. **ធ្វើវិសោធនកម្មឱ្យបានពេញលេញលើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ច្បាប់អង្គការសមាគម)** ដែលរំលោភលើកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

៩. **បញ្ឈប់រាល់ការជ្រៀងជ្រែក និងការត្រួតពិនិត្យតាមដានដោយបំពានរបស់រដ្ឋាភិបាលលើបណ្តាញផ្សព្វផ្សាយទាំងនៅលើ និងក្រៅប្រព័ន្ធអ៊ីនធឺណិត** និងបញ្ឈប់ការប្រើប្រាស់ច្បាប់ដែលមានលក្ខណៈគាបសង្កត់ដើម្បីបំបិទសំឡេង និងគ្រប់គ្រងបណ្តាញផ្សព្វផ្សាយឯករាជ្យ។

១០. **កសាងឡើងវិញនូវដំណើរការការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីអនុញ្ញាតឱ្យស្ថាប័ននេះអាចទទួលដោះស្រាយវិវាទការងារទាំងអស់** រួមទាំងវិវាទជុំវិញការបញ្ឈប់មេដឹកនាំសហជីព និងធានាថាពុំមានការរឹតត្បិតដល់កម្មករនិយោជិតទាំងអស់ក្នុងការស្វែងរកដំណោះស្រាយពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ទោះបីជាស្ថានភាពសហជីពយ៉ាងម៉េចក្តី។

១១. **ធានាឱ្យមានដំណោះស្រាយបន្ទាន់ យុត្តិធម៌ និងតម្លាភាពក្នុងករណីជម្លោះដីធ្លីទាំងអស់** តាមរយៈការផ្តល់សំណងដោយត្រឹមត្រូវដល់ជនរងគ្រោះក្នុងករណីទន្ទ្រានយកដីធ្លី និងបង្កើតប្រព័ន្ធផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីប្រកបដោយប្រសិទ្ធភាព និងត្រឹមត្រូវ ស្របពេលដែលត្រូវបញ្ឈប់រាល់ការយាយីលើសកម្មជនដីធ្លី និងសហគមន៍រងផលប៉ះពាល់នានា។

១២. **សហការជាមួយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងនីតិវិធីពិសេសទាំងឡាយក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ** ដើម្បីអនុញ្ញាតឱ្យស្ថាប័នទាំងនេះបំពេញអាណត្តិការងាររបស់ខ្លួនដោយពុំមានការជ្រៀតជ្រែក។

រដ្ឋាភិបាលកម្ពុជាគប្បីចាត់វិធានការឱ្យបានពេញលេញក្នុងន័យកែប្រែស្ថានភាពសិទ្ធិមនុស្ស ដែលកំពុងធ្លាក់ចុះយ៉ាងខ្លាំង ដើម្បីរក្សាឱ្យបាននូវការអនុគ្រោះពន្ធផ្នែកពាណិជ្ជកម្ម ឬបញ្ឈប់ការព្យួរជំនួយក្នុងលក្ខណៈទ្វេភាគីជាមួយនឹងម្ចាស់ជំនួយនានា។

យើងខ្ញុំសូមស្នើឱ្យរដ្ឋាភិបាលប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យទាំង១៣ខាងលើមេត្តាអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាឱ្យគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងរបស់សហភាពអឺរ៉ុបក្នុងការនាំមកនូវការគោរពសិទ្ធិមនុស្ស នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យជូនប្រជាពលរដ្ឋខ្មែរទាំងអស់។

សូមឯកឧត្តម និងលោកជំទាវទទួលនូវការគោរពយ៉ាងខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

អង្គការសង្គមស៊ីវិលអន្តរជាតិ និងសមាគមអ្នកបញ្ញាទិញអន្តរជាតិដែលគាំទ្រលិខិតចំហនេះ រួមមាន៖

1. Arab Network for Food Sovereignty – Regional
2. Article 19
3. ASEAN Parliamentarians for Human Rights (APHR)
4. Asian Democracy Network (ADN)
5. Asian Forum for Human Rights and Development (FORUM-ASIA)
6. Asian Network for Free Elections (ANFREL)
7. Asia Indigenous Peoples Pact (AIPP)
8. Business and Human Rights Resource Centre (BHRRC)
9. Civil Rights Defenders
10. CIVICUS
11. Clean Clothes Campaign (CCC)
12. EarthRights International
13. Ethical Trading Initiative (ETI)
14. Fair Labor Association (FLA)
15. FIAN Germany
16. Forest Peoples' Programme
17. Front Line Defenders
18. Global Witness
19. Human Rights Now (HRN)
20. Human Rights Watch (HRW)
21. International Commission of Jurists (ICJ)
22. International Federation for Human Rights (FIDH)
23. International Freedom of Expression Exchange (IFEX)
24. International Service for Human Rights (ISHR)
25. Pakistan Kissan Mazdoor Tehreek
26. People's Coalition on Food Sovereignty (PCFS) - Europe
27. People's Coalition on Food Sovereignty (PCFS) – Global
28. Pesticide Action Network Asia Pacific – Regional
29. Roots for Equity, Pakistan
30. Struggle to Economize Future Environment (SEFE), Cameroon
31. The B Team
32. World Organisation Against Torture (OMCT)
33. Zambia Social Forum